LONG BEACH UNIFIED SCHOOL DISTRICT

# សាលារៀនបិទទ្វាររហូតទៅដល់ថ្ងៃទី៣ខែឧសភាយ៉ាងឆាប់

ការបិទទ្វារនេះគឺដើម្បីបង្ការកាពារការឆ្លងរាលដាលនៃវីរុសកូរ៉ូណា ឬ កូវិឌ១៩ COVID-19។ ព័ត៌មានបន្ថែមទៀតនឹងមានផ្តល់ជូនតាមរយៈគេហទំព័រក្រសួងអប់រំឡុងប៊ីចនៅ **lbschools.net** និងតាមរយៈគេហទំព័រផ្ទាល់ខ្លួនរបស់សាលារៀននីមួយៗ អ៊ីមែល សារ សារសម្លេង បណ្តាញសង្គម និងតាមរយៈអនឡាញវីដេអូ នាថ្ងៃនិងសប្តាហ៍ខាងមុខនេះ។

# ការចែកអាហារសម្រាប់យកទៅញុំានៅផ្ទះ

- **ពីម៉ោង 11:30 ព្រឹកទៅដល់ 1 រសៀល ពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ**
- **មានអាហារថ្ងៃត្រង់និងអាហារសម្រន់ពេលព្រឹកសម្រាប់ថ្ងៃស្អែក**

ក្រសួងអប់រំ LBUSD នឹងផ្តល់អាហារសម្រាប់យកទៅញុំានៅផ្ទះដល់កុមារអាយុមួយឆ្នាំដល់១៨ឆ្នាំនៅក្នុងរយៈពេលដែលសាលាបិទទ្វារ ហើយមានចែកនៅគ្រប់សាលាទាំងអស់នៅក្នុងក្រសួងអប់រំឡុងប៊ីច LBUSD លើកលែងតែនៅសាលា Beach/Reid, Browning, CAMS, Lowell, Millikan, Naples, PAAL, Renaissance, Sato និង Stanford ។ អាហារនេះផ្តល់ឱ្យដោយមិនគិតតម្លៃដល់សិស្សទាំងអស់ មិនថាឡើយសិស្សនោះទៅរៀននៅសាលារៀនណាមួយក៏ដោយ ហើយមិនចាំបាច់បង្ហាញក្រដាសស្នាមអ្វីទេ។ សិស្សត្រូវតែមានវត្តមានមកយកអាហារដោយខ្លួនឯង។

# ឱកាសសិក្សានៅផ្ទះ

នៅក្នុងរយៈពេលដែលសាលាបិទទ្វារនេះ សិស្សនិងមាតាបិតាអាចប្រើគេហទំព័រឱកាសសិក្សានៅផ្ទះនៅ **lbschools.net** ដើម្បីរកមើលធនធានផ្សេងៗប្រចាំសាលារៀននិងគ្រូបង្រៀននីមួយៗ។

LONG BEACH UNIFIED SCHOOL DISTRICT
Home Learning
OPPORTUNITIES